# សេចក្តីថ្លែងការណ៍រួម

## សូមបញ្ឈប់ការធ្វើឧក្ខបុកម្ពេញទៅលើអង្គការសង់ត្រាល់ ពាក់ព័ន្ធនឹងរបាយការណ៍រោងចក្រកាន់តែប្រសើរ

ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

ការសម្រេចចិត្តរបស់ក្រសួងមហាផ្ទៃ ក្នុងការពិនិត្យមើល ទៅលើញត្តិដែលបានទទួល និងមើលអំពីលទ្ធភាពដែលអាចធ្វើការស៊ើបអង្កេតលើ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) ឬ អង្គការ សង់ត្រាល់ ពាក់ព័ន្ធនឹងការចេញផ្សាយរបាយការណ៍របស់ស្ថាប័ននេះ អំពីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (Better Factories Cambodia) គឺជាការឆ្លើយតបបែបអវិជ្ជមាន និងជាការព្យាយាមបំភិតបំភ័យទៅលើអង្គការមិនមែនរដ្ឋាភិបាល ដែលកំពុងធ្វើការងារដើម្បីជួយធ្វើឱ្យកាន់តែប្រសើរឡើង នូវសេរីភាពរបស់សហជីព សម្រាប់កម្មករ និងសហជីពនៅកម្ពុជា ។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា គឺជាកម្មវិធីមួយរួមគ្នារវាងពីអង្គការការងារអន្តរជាតិ (ILO) និង សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ។ ទាំងអង្គការការងារអន្តរជាតិ និង សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ យល់យ៉ាងច្បាស់ថា សង្គមស៊ីវិលគួរតែត្រូវបានអនុញ្ញាតឱ្យមានការចូលរួម ផ្តល់យោបល់ និងរិះគន់ដោយសេរី ទៅលើសកម្មភាពរបស់ស្ថាប័នទាំងពីរ ដើម្បីពង្រឹងប្រសិទ្ធិភាពការងាររបស់ខ្លួន ។ របាយការណ៍របស់អង្គការ សង់ត្រាល់ គឺជាសកម្មភាពចូលរួមយ៉ាងច្បាស់ ដោយអំពាវនាវដល់គម្រោងរោងចក្រកាន់តែប្រសើរ ឱ្យធ្វើការកែប្រែ ឱ្យរបាយការណ៍របស់ខ្លួនអាចឱ្យសហជីពនិងកម្មករទាញយកបាន ឱ្យបង្កើតយន្តការបណ្តឹងសារទុក្ខសម្រាប់ចំនុចដែលមិនត្រឹមត្រូវនៅក្នុងរបាយការណ៍វាយតម្លៃរបស់គម្រោង ។ របាយការណ៍ក៏បានលើកឡើងនូវបញ្ហាមួយចំនួនដែលកំពុងកើតមានឡើងនៅក្នុងវិស័យការងារ ។

អនុសាសន៍មួយចំនួននៃរបាយការណ៍នេះ ផ្តោតទៅលើកម្មករមួយចំនួន នៅក្នុងការវាយតម្លៃរោងចក្រដែលមានផលិតផលនាំចេញ ដែលស្ថិតនៅក្រោមគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ។ ការអះអាងដែលថា របាយការណ៍នេះ "ធ្វើឱ្យប៉ះពាល់អវិជ្ជមាន" ដល់គម្រោងរោងចក្រកាន់តែប្រសើរ ឬដល់ស្ថានភាពរបស់កម្មករ និងសហជីពនៅកម្ពុជា គឺមិនត្រឹមត្រូវនោះទេ ។ លើសពីនេះ សកម្មភាពនេះ ហាក់ដូចជាលេសមួយ ដើម្បីបំភិតបំភ័យស្ថាប័នមួយដែលកំពុងការពារសិទ្ធិកម្មករ ។ ការអះអាងនេះ គួរត្រូវបានបដិសេធឱ្យបានដាច់ហ័ស ពីគ្រប់ស្ថាប័នទាំងអស់ ដែលពាក់ព័ន្ធក្នុងការធានានូវការគោរពសិទ្ធិការងារ និងសិទ្ធិមនុស្ស នៅកម្ពុជា ។

យើងខ្ញុំមិនយល់ស្របចំពោះការអំពាវនាវដល់ក្រសួងដែលពាក់ព័ន្ធ ឱ្យមានការស៊ើបអង្កេតទៅលើការផ្តល់ជំនួយហិរញ្ញវត្ថុ និងដំណើរការសកម្មភាពការងាររបស់អង្គការ សង់ត្រាល់ ដោយយកមូលហេតុមិនត្រឹមត្រូវ ស្តីពីការជ្រៀតជ្រែកនិងការគ្រប់គ្រងរបស់រដ្ឋបរទេសលើសង្គមស៊ីវិលនៅកម្ពុជា ។ យើងខ្ញុំក៏យល់ផងដែរថា អង្គការ ឬកម្មករ

ឬសហជីពណាក៏ដោយ ក៏មានសេរីភាពក្នុងការមិនយល់ស្រប ទៅលើការរកឃើញនៅក្នុងរបាយការណ៍របស់អង្គការសង់ត្រាល់ ។ ប៉ុន្តែការស្នើសុំឱ្យមានការប្រើប្រាស់វិធានការរដ្ឋបាល ដើម្បីដាក់ទណ្ឌកម្មលើអ្នកធ្វើការងារលើសិទ្ធិកម្មករ គឺជាការរំលោភទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ។ សកម្មភាពនេះក៏ធ្លាប់ត្រូវបានធ្វើឡើង ដើម្បីវាយប្រហារ ផ្អាកឬព្យួរសកម្មភាពការងាររបស់ក្រុមសង្គមស៊ីវិលមួយចំនួនផងដែរ ។ ហើយសកម្មភាពនេះទៀតសោត ក៏មិនបានជួយធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជានោះទេ ។

យើងខ្ញុំសូមអំពាវនាវដល់អង្គការពលកម្មអន្តរជាតិ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា សូមទទួលស្គាល់ជាសាធារណៈ នូវតម្លៃនៃការសិក្សាស្រាវជ្រាវដែលរិះគន់សំដៅដល់ធ្វើឱ្យកាន់តែប្រសើរឡើងនូវដំណើរការ និងសកម្មភាពការងាររបស់គម្រោងនៃស្ថាប័នខ្លួន ។ យើងខ្ញុំអំពាវនាវដល់សហជីពដែលមិនយល់ស្រប អាចធ្វើការលើកឡើងនូវការព្រួយបារម្ភរបស់ខ្លួនជាសាធារណៈ និងធ្វើការសិក្សាស្រាវជ្រាវផ្ទាល់ខ្លួន ហើយអាចធ្វើការពិភាក្សាអំពីបញ្ហាទាំងនោះ ។ យើងខ្ញុំក៏សូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមមរក្សាជំហរ និងការប្ដេជ្ញាចិត្តរបស់ខ្លួន ក្នុងការគោរពនូវសេរីភាពក្នុងការបញ្ចេញមតិ និងអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ អាចធ្វើការងាររបស់ខ្លួន ដោយសេរី ជៀសផុតពីការរំលោភបំពាន និងការឆ្លើយតបជាអវិជ្ជមាន ដោយគ្រាន់តែស្ថាប័នទាំងនោះធ្វើការរិះគន់ ។

*សេចក្ដីថ្លែងការណ៍នេះ គាំទ្រដោយៈ*

1. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
2. សហគមន៍អមលាំង (កំពង់ស្ពឺ)
3. សហគមន៍ដីធ្លីអណ្ដូងត្របែក (ស្វាយរៀង)
4. សហគមន៍បុស្សស្នោរ (ត្បូងឃ្មុំ)
5. សហគមន៍បឹងពីរ (បាត់ដំបង)
6. សហគមន៍បឹងប្រាំ (បាត់ដំបង)
7. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
8. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ (CCIM)
9. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
10. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
11. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
12. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
13. បណ្ដាញយុវជនកម្ពុជា (CYN)
14. សហគមន៍ដីធ្លីដីខក្រោម (កោះកុង)

15. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
16. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
17. សហគមន៍ដក់ពរ (កំពង់ស្ពឺ)
18. អង្គការសមធម៌កម្ពុជា (EC)
19. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
20. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
21. សហគមន៍ជនជាតិដើមភាគតិចកួយ (ព្រះវិហារ)
22. សហគមន៍ជនជាតិដើមភាគតិចកួយឃុំងន (កំពង់ធំ)
23. សហគមន៍ជនជាតិដើមភាគតិចកួយឃុំប្រមេរុ ខេត្តព្រះវិហារ
24. សហគមន៍ដីធ្លីខេត្តប៉ៃលិន
25. សហគមន៍មានជ័យ (ស្វាយរៀង)
26. សហគមន៍អូរបាត់មាន់ (ឧត្តរមានជ័យ)
27. សហគមន៍ពង្រកជ័យល័ក្ខ (កំពត)
28. សហគមន៍ព្រៃឈើពេជ្រចង្វាល្អធើត (កំពង់ឆ្នាំង)
29. បណ្តាញសហគមន៍ព្រៃឡង់
30. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)
31. សហគមន៍ភ្នំក្រោម (សៀមរាប)
32. សហគមន៍ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)
33. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ)
34. អង្គការសមាគមជាងត្នោត (ស.ជ.ត)
35. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
36. សហគមន៍សាមគ្គីមោសហែក (ស្វាយរៀង)
37. សហគមន៍សាមគ្គីសង្កែពីរមានរិទ្ធិ (ព្រះវិហារ)
38. សហគមន៍ដីធ្លីស្រែប្រាំង (ត្បូងឃ្មុំ)
39. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)
40. សហគមន៍ដីធ្លី ឃុំត្នោតជុំ (ពោធិ៍សាត់)
41. សហគមន៍ដីធ្លីតានី (សៀមរាប)
42. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)
43. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)